**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# ប្រទេសកម្ពុជា៖ អ្នកជំនាញ អ.ស.ប ចោទជាសំណួរអំពី "ភាពត្រឹមត្រូវពិតប្រាកដ" នៃជ័យជំនះភ្លូកទឹកភ្លូកដីរបស់គណបក្សកាន់អំណាច

ទីក្រុងហ្សឺណែវ (២៦ កញ្ញា ២០១៨) - អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានចោទជាសំណួរអំពី "ភាពត្រឹមត្រូវពិតប្រាកដ" នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងខែកក្កដា ដែលសម្រាប់អាណត្តិរយៈពេលប្រាំឆ្នាំទៅមុខទៀត ធ្វើឱ្យគណបក្សប្រជាជនកម្ពុជារក្សាការកាន់អំណាចដែលខ្លួនធ្លាប់មានអស់រយៈពេលជាច្រើនទសវត្សរ៍ ដែល "បានតម្កល់ទុកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សមួយអន្លើក្នុងប្រវត្តិសាស្ត្រ"។

អ្នកស្រី រ៉ូណា ស្មីត បានមានប្រសាសន៍ដូច្នេះនៅមុនពេលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថាដំណើរការបោះឆ្នោតធ្លាប់មានភាពល្អប្រសើរឡើងជាលំដាប់ នេះបើនិយាយពីអនុលោមភាពទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា។

ប៉ុន្តែនៅក្នុង[របាយការណ៍]មួយស្តីពីការបោះឆ្នោតដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអ្នកស្រីបានមានប្រសាសន៍ថា ការរំលាយគណបក្សប្រឆាំងដ៏ធំមួយ និងការហាមឃាត់សមាជិកជាន់ខ្ពស់ជាច្រើនរូប នៃអតីតគណបក្សប្រឆាំងមួយនេះមិនឲ្យធ្វើសកម្មភាពនយោបាយរយៈពេល ៥ ឆ្នាំ "បានចោទជាសំណួរយ៉ាងខ្លាំងចំពោះភាពត្រឹមត្រូវពិតប្រាកដនៃការបោះឆ្នោតនេះ"។

អ្នកស្រី ស្មីត បានមានប្រសាសន៍ប្រាប់ក្រុមប្រឹក្សាកាលពីរសៀលថ្ងៃពុធនេះថា គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចមួយនេះ ទទួលបានអាសនៈសភាទាំងអស់នៅក្នុងការបោះឆ្នោត។ "ដូច្នេះ ប្រទេសនេះបើតាមព្រឹត្តន័យ គឺជារដ្ឋមួយឯកបក្ស។ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញត្រូវតម្កល់ទុកមួយអន្លើក្នុងប្រវត្តិសាស្ត្រ សម្រាប់ រយៈពេល ៥ ឆ្នាំ ទៅមុខទៀត ដែលជានីតិកាលរដ្ឋសភាបច្ចុប្បន្ននេះ"។

អ្នកស្រីបានមានប្រសាសន៍ថា ការប្រើច្បាប់ដើម្បីរឹតត្បិតការជជែកពិភាក្សាដេញដោល និងការកំណត់គោលដៅទៅលើប្រព័ន្ធផ្សព្វផ្សាយ គូបក្សជិបក្សនយោបាយ អង្គការសង្គមស៊ីវិល និងបុគ្គលឯកជន រួមទាំង តាមរយៈការប្រើប្រាស់ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ផងដែរនោះ បានធ្វើឲ្យរួមតូចនូវលំហសម្រាប់ការពិភាក្សាដេញដោលខាង

នយោបាយពិតប្រាកដ ដែលជាកត្តាមួយដ៏សំខាន់ សម្រាប់ការទទួលបាននូវសិទ្ធិចូលរួមក្នុងការអនុវត្តកិច្ចការសាធារណៈ។

អ្នកស្រី ស្មិត បានមានប្រសាសន៍ថា "ការជជែកពិភាក្សាដេញដោលខាងនយោបាយជាលក្ខណៈពហុបក្ស គឺជាធាតុសំខាន់ជាសារវន្តក្នុងការកំណត់អំពីលក្ខណៈប្រកួតប្រជែងពិតប្រាកដនៅក្នុងការបោះឆ្នោត។"

អ្នកស្រីបានលើកឡើងផងដែរអំពីកង្វល់ទាក់ទងនឹងរបាយការណ៍ដែលថាអ្នកបោះឆ្នោតបានទទួលរងនូវការគំរាមកំហែង និងការបំភិតបំភ័យ បន្ទាប់ពីមានការអំពាវនាវឲ្យធ្វើពហិការការបោះឆ្នោត ហើយដែលគណៈកម្មាធិការសិទ្ធិមនុស្សបានចាត់ទុកថាការអំពាវនាវនោះគឺជាការអនុវត្តសេរីភាពបញ្ចេញមតិដែលត្រូវបានអនុញ្ញាត ជាពិសេសក្នុងបរិបទនៃការបោះឆ្នោតមួយដែលមិនមានលក្ខណៈជាកាតព្វកិច្ចសម្រាប់ប្រជាពលរដ្ឋនោះ។

អ្នកស្រី ស្មិត បានមានប្រសាសន៍នៅក្នុងរបាយការណ៍ថា "របាយការណ៍អំពីការគំរាមកំហែងដល់អ្នកបោះឆ្នោតក្នុងករណីពួកគេមិនទៅបោះឆ្នោត គឺជាក្តីកង្វល់ជាពិសេស៖ ម្រាមដៃមានជាប់ស្នាមទឹកខ្មៅ ដែលជានិមិត្តរូបនៃសេចក្តីសង្ឃឹម និងសេរីភាពកាលពីពេលអតីតកាល បានក្លាយជានិមិត្តរូបនៃការបង្ខិតបង្ខំទៅវិញ"។

បន្ទាប់ពីមានការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ ឥស្សរជនគណបក្សប្រឆាំង និងតួអង្គសង្គមស៊ីវិលមួយចំនួនត្រូវបានដោះលែងពីការឃុំឃាំង ហើយអ្នកខ្លះត្រូវបានលើកលែងទោស។ ក្នុងរយៈពេលមិនយូរប៉ុន្មានក្រោយពីលោក កឹម សុខា ដែលជាមេដឹកនាំអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានតុលាការពន្យាពេលឃុំខ្លួនរបស់លោកកាលពីខែសីហា មក គាត់ក៏ត្រូវបានគេយកចេញពីពន្ធនាគារទៅឃុំឃាំងក្នុងផ្ទះវិញ។

អ្នកស្រីបានមានប្រសាន៍ថា ទោះជាមានការដោះលែងឲ្យមានសេរីភាពឡើងវិញគឺជារឿងដែលគួរឲ្យលើកទឹកចិត្តក៏ដោយ ក៏គេកត់សម្គាល់ឃើញថា មនុស្សភាគច្រើនដែលត្រូវបានដោះលែងកាលពីពេលថ្មីៗនេះ នៅតែស្ថិតនៅក្រោមការត្រួតពពិនិត្យតាមផ្លូវតុលាការដដែល។ នេះមានន័យថា ការចោទប្រកាន់ទៅលើពួកគេទាំងនោះមិនត្រូវបានទម្លាក់ចោលនៅឡើយទេ ហើយពួកគេក៏មិនទាន់ត្រូវបានរកឃើញថាគ្មានពិរុទ្ធភាពនៅឡើយដែរ។ ផ្ទុយទៅវិញពួកគេនៅតែស្ថិតនៅក្រោមការគំរាមកំហែងដែលថាពួកគេនឹងអាចចាប់ឃុំខ្លួនសាជាថ្មីទៀត នៅពេលណាក៏បានស្របពេលដែលពួកគេកំពុងតែរង់ចាំសវនាការជំនុំជម្រះរឿងក្តីរបស់ពួកគេនោះ។

អ្នកស្រី ស្មិត បានលើកឡើងផងដែរអំពីករណីពាក់ព័ន្ធនឹងបុគ្គលិក និងអតីតបុគ្គលិករបស់អង្គការសិទ្ធិមនុស្សអាដហុកដែលនៅតែស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្រោយពេលដែលពួកគេទាំងនោះត្រូវបានដោះលែងនៅក្នុងខែមិថុនា ឆ្នាំ ២០១៧ បន្ទាប់ពីត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៤២៧ ថ្ងៃ។ តុលាការបានប្រកាសសាលក្រមលើករណីរបស់ពួកគេកាលពីរសៀលថ្ងៃនេះ ក្រោយការចាប់ខ្លួនពួកគេអស់រយៈពេលជិតពីរឆ្នាំកន្លះមក។

អ្នករាយការណ៍ពិសេស បានគូសបញ្ជាក់ថា នេះគឺជាការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តី ក្នុងរយៈពេលមួយសមហេតុសម។

អ្នកស្រី ស្មីត បានមានប្រសាសន៍ថា សកម្មជនទាំងប្រាំរូបត្រូវបានផ្តន្ទាទោសពីបទសូកប៉ាន់សាក្សី និងទទួលបានការព្យួរទោសមួយផ្នែកនៃទោសជាប់ពន្ធនាគារ។ "នៅក្នុងសាច់រឿងនេះទាំងមូល បានចោទជាសំណួរយ៉ាងខ្លាំងអំពីតួនាទី និងសុចរិតភាពនៃដំណើរការទាំងមូលរបស់តុលាការ និងហាក់ដូចជាមិនមានអ្វីក្រៅតែពីការធ្វើទុក្ខបុកម្នេញខាងនយោបាយទៅលើសង្គមស៊ីវិលឡើយ"។

អ្នករាយការណ៍ពិសេសបានអំពាវនាវឲ្យរដ្ឋាភិបាល ធ្វើការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកំពស់ស្ថានភាពសិទ្ធិមនុស្ស។ "ខ្ញុំសូមលើកទឹកចិត្តឲ្យរដ្ឋាភិបាលបង្កើតបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល ដើម្បីធ្វើការងាររបស់ខ្លួន។ នេះជាជំហានដ៏សំខាន់មួយក្នុងការបង្កើតលំហសម្រាប់ការជជែកពិភាក្សាដេញដោលដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ ជុំវិញបញ្ហាបន្ទាន់បង្ខំនានា ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាពស្ថិតស្ថេរយូរអង្វែងរបស់ប្រទេសកម្ពុជា"។

ចប់

*អាចរកបានតាមអនឡាញ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា*

*អាចរកបានតាមអនឡាញ៖ របាយការណ៍បន្ថែមស្តីពីសិទ្ធិមនុស្ស និងការបោះឆ្នោត*

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការងារឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគាត់បំរើការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*សូមស្វែងរកមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*អ្នកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org)*
*លោក ម៉ាស៍មូដ ហ្គារហ្គា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬអ៊ីមែល៖ mgarga@ohchr.org )*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉ីមី ឡូរង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីមែល jlaurence@ohchr.org)*

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបាន អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្អែកខាងអត្ថបទដែលត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា «មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ»។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី ៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖***
*www.standup4humanrights.org.*